**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**

**រៀបចំបុណ្យជាតិ អន្តរជាតិ**

លេខៈ០៩/២០១៧ គជបអ

# ផែនការណែនាំ

## ស្តីពីការរៀបចំខួបលើកទី ២៤ ទិវាប្រកាសរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

យោង : ព្រះរាជក្រឹត្យលេខ នស/រកត ០៨០៥/៣៥៤ ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល **គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ** ទៅជា **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**។

-អនុក្រឹត្យលេខ ២២៣ អនក្រ-បក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីប្រតិទិនឈប់សម្រាកការងារ របស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៧ ។

-សារាចរណែនាំ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ លេខ ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ ។

ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ជាថ្ងៃដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់កំពូលប្រកបដោយខ្លឹមសារយ៉ាងជ្រាលជ្រៅលើគ្រប់វិស័យ ដែលសភាធម្មនុញ្ញបានអនុម័ត ត្រូវបានព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ឡាយព្រះហស្តលេខាលើព្រះរាជក្រម ប្រកាសឲ្យប្រើជាផ្លូវការក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យប្រជារាស្ត្រខ្មែរពង្រឹងបានសាមគ្គីភាព ឯកភាពជាតិរឹងមាំ រក្សាការពារបូរណភាពទឹកដី ប្រជាធិបតេយ្យថ្លៃថ្លា និងអរិយធម៌អង្គរដ៏បវរ និងសម្បូរណ៍រុងរឿង ។

ដើម្បីសម្តែងនូវអំណរសាទរគោរពដោយស្មោះត្រង់ និងរំលឹកទិវាជាប្រវត្តិសាស្ត្រចំពោះរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់រដ្ឋ **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** សូមធ្វើការណែនាំដូចតទៅ៖

១-**គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត** ត្រូវចាត់តាំងរៀបចំខួបលើកទី ២៤ នៃទិវាប្រកាសរដ្ឋធម្មនុញ្ញ ឲ្យបានសមស្របតាមលទ្ធភាពជាក់ស្តែង និងចាត់ចែងតុបតែងលម្អ ទង់ជាតិ ទង់ក្តោប បដាពាក្យស្លោក និងបំភ្លឺភ្លើងពណ៌នៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី ខេត្ត និងមន្ទីរ អង្គភាព ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រប់វត្តអារាម អគារសាធារណៈ ក្រុមហ៊ុន រោងចក្រ សហគ្រាស សាលារៀន ព្រមទាំងលំនៅដ្ឋានប្រជារាស្ត្រ ដើម្បីអបអរសាទរ នៃទិវាប្រកាសរដ្ឋធម្មនុញ្ញ។

២-**ក្រសួងព័ត៌មាន** ណែនាំបណ្តាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន តាមដានយកព័ត៌មាន ធ្វើការផ្សព្វផ្សាយនូវខ្លឹមសារនៃរដ្ឋធម្មនុញ្ញឲ្យបានទូលំទូលាយ ។

៣-**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ណែនាំគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ចាត់តាំងក្រុមតន្ត្រីសិល្បបុរាណ សម័យ សម្តែងជូនប្រជារាស្ត្រទស្សនាកម្សាន្តសប្បាយ នៅតាមទីសាធារណៈ ដើម្បីចូលរួមអបអរសាទរក្នុងទិវាជាប្រវត្តិសាស្ត្រនេះ នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៧ ។

វិថីឧកញ៉ា ឈន លេខ ២៤០ រាជធានីភ្នំពេញ Tel/Fax: (855) 023 986 370 - (855) 023 986 374 - (855) 023 213 956 E-mail: [illegible]

៤-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ណែនាំដល់អង្គភាពក្រោមឱវាទ ឲ្យសហការការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ ធានាសុវត្ថិភាពល្អប្រសើរ ក្នុងការរៀបចំទិវាប្រកាសរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងខេត្ត ចាត់តាំងអនុវត្តតាមស្មារតី នៃផែនការណែនាំនេះឲ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៧

ជ. គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

ប្រធាន

សម្តេចចៅហ្វាវាំង ធរសៀវជ័យ អធិបតីស្រីទ្វារ គង់ សំអុល

<u>កន្លែងទទួល</u>

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ទីស្តីការគណៈរដ្ឋមន្ត្រី

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ

"ដើម្បីជូនជ្រាប"

គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត

"ដើម្បីសហការអនុវត្ត"

ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក
# សម្រាប់ប្រើក្នុងទិវាប្រកាសរដ្ឋធម្មនុញ្ញ
# នៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ២០១៧

១- អបអរសាទរខួបលើកទី ២៤ ទិវាប្រកាសរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៣- ជយោ! សន្តិភាព និងការអភិវឌ្ឍ

៤- ជយោ! ព្រះរាជាណាចក្រកម្ពុជា

៥- ជាតិ សាសនា ព្រះមហាក្សត្រ

៦- ពលរដ្ឋគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

៧- ការពារដាច់ខាត រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

៨- ជយោ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា